ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១០៣/១១-ហ៊ុយ ចៀន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណេន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លះ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខូ**
អាសយដ្ឋាន ៖ ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៨៩ ៨៤៥ ៨៨៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖
១-កញ្ញា កើត កុសនី ជំនួយការរដ្ឋបាល
២-លោក ម៉ុម ធន ទីប្រឹក្សាច្បាប់
តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖
១-កញ្ញា កើត កុសនី ជំនួយការរដ្ឋបាល
២-លោក ម៉ុម ធន ទីប្រឹក្សាច្បាប់

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ)**
អាសយដ្ឋាន ៖ ផ្ទះលេខ ២,៣ G ផ្លូវលេខ ២៦BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៨៩ ៩៦០ ៨៦០ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

១- លោក មូ ឈាង មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកម្ពុជា

២- លោក ជឹម យឿង មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកម្ពុជា

៣- លោក នឹម សារឿន ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ

៤- លោក ហុង ឡៃ អនុប្រធានសហជីព

៥- កញ្ញា វ៉ា គន្ធា លេខាធិការសហជីព

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖

១- លោក មូ ឈាង មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកម្ពុជា

២- លោក ជឹម យឿង មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកម្ពុជា

៣- លោក នឹម សារឿន ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ

៤- លោក ហុង ឡៃ អនុប្រធានសហជីព

៥- កញ្ញា វ៉ា គន្ធា លេខាធិការសហជីព

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-ទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពស៊ីខៅខ្វ និងសកម្មជនចូលធ្វើការជាធម្មតាវិញ ហើយត្រូវគិតប្រាក់រំលឹកផង ។

២-ស្នើឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងសហជីព និងថ្នាក់ដឹកនាំសហជីព ហើយសកម្មជនសហជីព ។

៣-ស្នើឱ្យក្រុមហ៊ុននៅពេលគ្មានការងារឱ្យកម្មករធ្វើត្រូវផ្តល់ប្រាក់ឈ្នួលមួយរយភាគរយពេញ មិនត្រូវកាត់ប្រាក់ឈ្នួលជូសការឈប់សម្រាកប្រចាំឆ្នាំឡើយ ។

៤-ស្នើឱ្យក្រុមហ៊ុន នៅពេលដែលកម្មករមកធ្វើការយឺត ២០ នាទី កាត់ប្រាក់រង្វាន់ការងារទៀងទាត់តាមសមាមាត្រ ចំនួននាទី ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាម ជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ។

ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៨៩៣ កប/អក/វក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ។

**សវនាការ និង សន្ទេបនីតិវិធី**

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖

- លើកទី១ ៖ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ៨:៣០ នាទី ព្រឹក) ។
- លើកទី២ ៖ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ (វេលាម៉ោង ៨:៣០ នាទី ព្រឹក) ។

បញ្ហានៃនីតិវិធីៈ

នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១១ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៤ ចំណុច លើការទាមទារចំនួន ០៤ ចំណុច។ ចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ៨៩៣ កប/អក/វក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៤ ចំណុចនេះចំនួនពីរលើក។ សវនាការលើកទី១ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក និងសវនាការលើកទី២ ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១១ វេលាម៉ោង ០៨:៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ភាគីកម្មករនិយោជិត និងភាគីនិយោជក ឯកភាពគ្នាពន្យារកាលបរិច្ឆេទចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ទៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១១។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានធ្វើការផ្សះផ្សាចំណុចមិនសះជាចំនួន ០៤ ចំណុចនេះ បន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០២ ចំណុច គឺចំណុចវិវាទទី៣ និងទី៤ និងមិនសះជាចំនួន ០២ ចំណុច គឺចំណុចវិវាទទី១ និងទី២ ។ ដោយចំណុចវិវាទទី១ និងទី២ ពាក់ព័ន្ធគ្នា ដូចនេះ កម្មករនិយោជិតបានយល់ព្រមដាក់បញ្ចូលចំណុចវិវាទទាំងពីរបញ្ចូលគ្នា។ ចំពោះចំណុចវិវាទទី៣ និងទី៤ ភាគីទាំងពីរព្រមព្រៀងគ្នាផ្ទាល់មាត់នៅក្នុងសវនាការថា ៖

**ចំណុចវិវាទទី៣:** ក្រុមហ៊ុននឹងផ្ដល់ប្រាក់ឈ្នួល ១០០ ភាគរយ ឱ្យកម្មករនិយោជិត នៅពេលដែលក្រុមហ៊ុនមិនមានការងារឱ្យកម្មករនិយោជិតធ្វើ ហើយក្រុមហ៊ុនមិនបានជូនដំណឹងទៅកម្មករនិយោជិតមុន។ ក្រុមហ៊ុននឹងផ្ដល់ប្រាក់ឈ្នួល ៥០ ភាគរយ ឱ្យកម្មករនិយោជិត នៅពេលដែលក្រុមហ៊ុនមិនមានការងារឱ្យកម្មករនិយោជិតធ្វើ ហើយក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតមុនមួយថ្ងៃ។

**ចំណុចវិវាទទី៤:** ក្រុមហ៊ុនឯកភាពថា នៅពេលកម្មករនិយោជិតមកធ្វើការយឺតជាក្រុម ដោយសារឡានបែកកង់ ឬដោយសារស្ទះចរាចរណ៍ ក្រុមហ៊ុននឹងមិនកាត់ប្រាក់រង្វាន់ការងារទៀងទាត់របស់កម្មករនិយោជិតទេ។ ចំពោះកម្មករនិយោជិត ដែលធ្វើដំណើរតាមមធ្យោបាយរៀងៗខ្លួន ដែលមកធ្វើការយឺតមិនលើសពី ២០ នាទី ក្នុងមួយខែ ក្រុមហ៊ុននៅតែរក្សាអនុវត្តគោលការណ៍កាត់ប្រាក់រង្វាន់ការងារទៀងទាត់ដូចការអនុវត្តសព្វថ្ងៃ។

ដោយសារភាគីទាំងពីរជាហត្ថលេខីនៃអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ ស្ដីពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈក្នុងឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ ដូចនេះ ក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងបែងចែកសេចក្ដីសម្រេចនៃចំណុចវិវាទជាពីរ គឺចំណុចវិវាទអំពីសិទ្ធិ និងចំណុចវិវាទអំពីប្រយោជន៍។ ភាគីទាំងពីរមិនមានសិទ្ធិប្ដឹងជំទាស់លើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើចំណុចវិវាទអំពីសិទ្ធិនោះទេ ព្រោះភាគីទាំងពីរបានព្រមព្រៀងគ្នា ឱ្យសេចក្ដីសម្រេចនេះ ជាសេចក្ដីសម្រេចដែលជាប់កាតព្វកិច្ចតាមរយៈអនុស្សារណៈនៃការយោគយល់គ្នាចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០ រួចហើយ។ ប៉ុន្តែ ភាគីអាចប្ដឹងជំទាស់ទៅលើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើវិវាទអំពីប្រយោជន៍ ប្រសិនបើភាគីជ្រើសរើសយកសេចក្ដីសម្រេចមិនជាប់កាតព្វកិច្ចចំពោះវិវាទអំពីប្រយោជន៍។ ការប្ដឹងជំទាស់របស់ភាគីទៅនឹងសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលលើចំណុចវិវាទអំពីប្រយោជន៍ នឹងមិនបណ្ដាលឱ្យប៉ះពាល់ទៅដល់កាតព្វកិច្ចក្នុងការអនុវត្តសេចក្ដីសម្រេចដែលជាវិវាទអំពីសិទ្ធិទេ ដោយអនុលោមតាមស្មារតីនៃអនុស្សារណៈនៃការយោគយល់គ្នាខាងលើនោះ។ ចំពោះសំណុំរឿងនេះ ភាគីទាំងពីរជ្រើសរើសសេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីប្រយោជន៍។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី ÷**

ក-សាក្សីអព្យាក្រិត ៖

| | |
|---|---|
| ១-លោក Johsonho | នាយកក្រុមហ៊ុន ហ៊ុយចៀន សាខាតាកែវ |
| ២-លោក អ៊ុង សំអាត | សន្តិសុខ |
| ៣-កញ្ញា លេង ភារម្យ | QC |
| ៤-កញ្ញា ងយ ដា | QC |
| ៥-កញ្ញា ញ៉ើន សុផា | QC |

ខ-សាក្សីក្នុងនាមនិយោជក ៖ លោកស្រី Li Yan Qaun

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១-ប័ណ្ណប៉ាតង់ឆ្នាំ២០១១ ក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប របស់សាខាពន្ធដារខេត្តតាកែវ លេខ ០៦១ អពដ.សខ.តក ចុះខែមីនា ឆ្នាំ២០១១ ។

២-វិញ្ញាបនប័ត្របង្កើតរោងចក្រ ហ៊ុយចៀន (ខេមបូឌា) ខប សាខាទី២ លេខ ០៨៦ ឧរថ.កឧ.បរ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ២០០៨ ។

៣-លិខិតបញ្ជាក់សាខាក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប "ខេត្តតាកែវ" លេខ ១០៧ អពដ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ។

៤-របាយការណ៍អធិការកិច្ចការងាររបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តតាកែវ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៩ ។

៥-ប័ណ្ណប៉ាតង់ឆ្នាំ២០១១ ក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប លេខ DLT.033361.2011 ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១ ។

៦-វិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីក្នុងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប លេខ ០៨៤២ ពណ.បអព ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១១ ។

៧-របាយការណ៍អធិការកិច្ចការងាររបស់នាយកដ្ឋានអធិការកិច្ចការងារចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១១ ។

៨-សារណាសង្ខេបស្តីពីលោក នឹម សារឿន ។

៩-អនុស្សរណៈរួមរវាងក្រុមហ៊ុន ហ៊ុយចៀន និងសហព័ន្ធសហជីពខ្មែរ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១០ ។

១០-លិខិតបញ្ជាក់ការជ្រើសរើសរបស់លោក នឹម សារឿន ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៩ ។

១១-តារាងឯកសារបុគ្គលិក ឈ្មោះ នឹម សារឿន ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ។

១២-លិខិតបញ្ជាក់ការជ្រើសរើសរបស់កញ្ញា វ៉េន ស្រីបុល ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ។

១៣-លិខិតបញ្ជាក់ការជ្រើសរើសរបស់លោក នឹម សុផាន់ណា ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ ។

១៤-សំបុត្របញ្ជាក់កំណើតឈ្មោះ នឹម សុផាន់ណា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ។

១៥-លិខិតបញ្ជាក់ការជ្រើសរើសឈ្មោះ នៅ សុខភាព ចុះទី០៦ ខែកក្កដា ឆ្នាំ២០១០ ។

១៦-តារាងឯកសារបុគ្គលិកឈ្មោះ នៅ សុខឃី ។

១៧-លិខិតបញ្ជាក់ការជ្រើសរើសឈ្មោះ សែត កុសល ចុះទី០៣ ខែមិថុនា ឆ្នាំ២០១១ ។

១៨-ប័ណ្ណសំគាល់ខ្លួននៃរោងចក្រ ហ៊ុយចៀន រាជធានីភ្នំពេញ និង រោងចក្រ ហ៊ុយចៀន ខេត្តតាកែវ ។

១៩-របៀបបែងចែកប័ណ្ណសំគាល់ខ្លួន ។

២០-តារាងប្រាក់ខែ ក្នុងខែមីនា មេសា ឧសភា និងមិថុនា ឆ្នាំ២០១១ ។

២០-លិខិតរបស់ក្រុមហ៊ុន ហ៊ុយចៀន ស្តីពីការផ្តល់អត្ថប្រយោជន៍ជូនកម្មករនិយោជិត ដែលត្រូវបានធ្វើការប្តូរទីតាំងបំពេញការងារ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១ ។

២១-លិខិតរបស់ក្រុមហ៊ុន ហ៊ុយចៀន ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ដែលរៀបរាប់ពីបញ្ហាវិវាទនៅក្នុងក្រុមហ៊ុន ហ៊ុយចៀន ។

២២-លិខិតបញ្ជាក់ការជ្រើសរើសរបស់ឈ្មោះ មួង សារីម ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ។

២៣-តារាងឯកសារបុគ្គលិករបស់ឈ្មោះ មួង សារីម ។

២៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ឈ្មោះ មួង សារីម ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៨ ។

២៥-លិខិតបញ្ជាក់ទីលំនៅរបស់ឈ្មោះ មួង សារីម ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ ។

២៦-លិខិតបញ្ជាក់កិរិយាមាយាទរបស់ឈ្មោះ មួង សារីម ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ ។

២៧-លិខិតធានាពីអាណាព្យាបាលរបស់ឈ្មោះ មួង សារីម ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៩ ។

២៨-លិខិតណែនាំចំពោះឈ្មោះ មួង សារីម ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៩ ។

២៩-លិខិតធានាអះអាងរបស់ឈ្មោះ មួង សារីម ក្នុងការគោរពតួនាទី ការងារ និងបទបញ្ជាផ្សេងៗរបស់ក្រុមហ៊ុនក្នុងពេលបំពេញការងារ ។

៣០-កិច្ចសន្យារបស់ក្រុមហ៊ុន ហ៊ុយចៀន ។

៣១-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប លេខ ៣៣៣ ពណ.នតក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០៦ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១-លិខិតធានាអះអាងរបស់ឈ្មោះ វ៉ា គន្ធា ក្នុងការគោរពតួនាទី ការងារ និងបទបញ្ជាផ្សេងៗរបស់ក្រុមហ៊ុនក្នុងពេលបំពេញការងារ ។

២-លិខិណែនាំរបស់ឈ្មោះ វ៉ា គន្ធា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៩ ដែលបានណែនាំអោយឈ្មោះ នឹម សារឿន អោយចូលធ្វើការនៅផ្នែកគ្រោង ។

៣-កំណត់ហេតុសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហ៊ុយចៀន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១១ ។

៤-កំណត់ហេតុនៃផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ហ៊ុយចៀន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ។

៥-លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា លេខ ១១៨/១១ សបក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន ហ៊ុយចៀន ស្តីពីការជូនដំណឹងបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរស្បែកជើងប្រចាំក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប.អិលធីឌី ។

៦-បង្កាន់ស៊ុំចុះបញ្ជិកាសហជីព ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ ។

៧-សាលាកប័ត្រផ្ញើរសេវា EMS ក្នុងប្រទេស ។/

៨-លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាលេខ ១១៥/១១ សបក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន ហ៊ុយចៀន ស្តីពីការជូនដំណឹងលទ្ធផលបោះឆ្នោតបង្កើតសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរស្បែកជើងប្រចាំក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា)ខប. អិលធីឌី ។

៩-លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជាលេខ ០៧២/១១ សបក ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១១ គោរពជូនលោកនាយកក្រុមហ៊ុន ហ៊ុយចៀន ស្តីពីការស្នើសុំជួបពិភាក្សាលើលក្ខខណ្ឌការងារមួយចំនួន និងការបញ្ជាក់ថ្នាក់ដឹកនាំសហជីពស៊ីខៅឌូពីការងារ ។

១០-កំណត់ហេតុស្តីពីការសន្តិសុខក្រុមហ៊ុន ហ៊ុយចៀន ឈ្មោះ អ៊ិន ស៊ីដេត បានយកលិខិតជូនដំណឹងបោះឆ្នោតបង្កើតសហជីពរបស់ CCAWDU ប្រចាំក្រុមហ៊ុន ហ៊ុយចៀន ឱ្យមក CCAWDU វិញ ចុះថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១១ ។

១១-សេចក្តីជូនដំណឹងផ្លាស់ប្តូរកន្លែងធ្វើការរបស់ក្រុមហ៊ុន ហ៊ុយចៀន តាកែវ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០១១ ពីការផ្លាស់ប្តូរការងារបុគ្គលិក ៦ នាក់ឈ្មោះ ជឹង វីនយ៉ាវ នឹម សារឿន វ៉េន ស្រីបុល នឹម សុផាន់ណា នៅ សុខឃី ។

១២-លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ៧២៤ កប/អក/វក ចុះថ្ងៃទី០៤-ខែកក្កដា ឆ្នាំ២០១១ ជំរាបមកលោក នឹម សារឿន ស្តីពីការស្នើសុំចុះបញ្ជីការប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប. អិលធីឌី។

១៣-លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ៩៣០ កប/អក/វក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១១ ជំរាបមកលោក នឹម សារឿន ស្តីពីការស្នើសុំចុះបញ្ជីការប្រជាធិបតេយ្យកម្មករកាត់ដេរស្បែកជើងនៃក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប. អិលធីឌី ។

១៤-ប័ណ្ណសំគាល់ខ្លួនកម្មករក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខូ. អិលធីឌី ។

១៥-សារណាលេខ ១០៧/១១ សបក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ។

១៦-សារណាបញ្ជាក់បន្ថែមលេខ ១០៨/១១ សបក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ។

១៧-លិខិតផ្ទេរសិទ្ធិរបស់ថ្នាក់ដឹកនាំ និងជាកម្មករនៃក្រុមហ៊ុន ហ៊ុយចៀន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ៊ុយចៀន លេខ ៨៩៣ កប/អក/វក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១១ ។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ៊ុយចៀន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញនិយោជកចូលរួមសវនាការលើកទី១ លេខ ៥៨៩ កប/អក/វក/ លកអ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៥៨៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ ។

៣-លិខិតអញ្ជើញនិយោជកចូលរួមសវនាការលើកទី២ លេខ ៦០៤ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ។

៤-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៦០៥ កប/អក/វក/លកអ.ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ។

៥-ការព្រមព្រៀងយកសេចក្តីបង្គាប់ជាប់កាតព្វកិច្ចលើចំណុចវិវាទអំពីសិទ្ធិ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- សហជីពកម្មករនិយោជិត ដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ គឺសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំរោងចក្រ ហ៊ុយចៀន។ សហជីពទើបតែបង្កើត មិនទាន់មានបញ្ជិកាសហជីពពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ។ សហជីពមានសមាជិកសរុប ៣០០ នាក់។
- ភាគីកម្មករនិយោជិត ទឹម សារឿន, ជឹម វីនយ៉ាវ, នីម សុផាន់ណា, និង នៅ សុខឃី បានធ្វើលិខិតផ្ទេរសិទ្ធិជូនសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (ស៊ីខៅឌូ) ជាតំណាងក្នុងដំណើរការដោះស្រាយក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទទី១ និងទី២ : ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន អនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីព និងសកម្មជនចូលធ្វើការនៅកន្លែងដើមវិញ នៅភ្នំពេញ និងសងប្រាក់រំលឹក**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព និងសកម្មជនសហជីព មានកម្មករនិយោជិតឈ្មោះ ទឹម សារឿន ប្រធានសហជីព កម្មករនិយោជិតឈ្មោះ វ៉ា គន្ធា ជាលេខាធិការសហជីព កម្មករនិយោជិតឈ្មោះ ជឹម វីនយ៉ាវ ជាសកម្មជនសហជីព កម្មករនិយោជិតឈ្មោះ នីម សុផាន់ណា ជាសកម្មជនសហជីព និងកម្មករនិយោជិតឈ្មោះ នៅ សុខឃី ជាសកម្មជនសហជីព ចូលធ្វើការវិញ។

- ភាគីនិយោជកដែលតំណាងដោយរដ្ឋបាល និងទីប្រឹក្សាច្បាប់ប្រចាំនៅក្រុមហ៊ុន ហ៊ុយ ចៀន នៅភ្នំពេញ បញ្ជាក់ថា កម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿងនេះ មិនមែនជាកម្មករនិយោជិតរបស់ក្រុមហ៊ុន ហ៊ុយចៀន នៅភ្នំពេញទេ មានតែកម្មករនិយោជិត ៦ា៉ គន្ធា ប៉ុណ្ណោះ ដែលជាកម្មករនិយោជិត នៅក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ ក្រៅពីនេះ ជាកម្មករនិយោជិតក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ។

- ក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ មានការគ្រប់គ្រងរដ្ឋបាលផ្សេង ពីក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ។ ដូច្នេះ ក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ មិនអាចទទួលយកកម្មករនិយោជិតរបស់សាខាខេត្តតាកែវ ចូលធ្វើការវិញទេ ចំណែកឯកម្មករនិយោជិត ៦ា៉ គន្ធា ក្រុមហ៊ុនមិនដោះស្រាយក្នុងសំណុំរឿងនេះទេ ព្រោះមិនមានឈ្មោះក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ និងក្រុមហ៊ុន ហ៊ុយចៀន សាខាតាកែវ ជាក្រុមហ៊ុនតែមួយ ព្រោះគ្មានបញ្ជិកាពាណិជ្ជកម្មផ្សេងគ្នា ហើយក្រុមហ៊ុន ហ៊ុយចៀន ខេត្តតាកែវ គឺ ជាសាខាក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញប៉ុណ្ណោះ ។

- ក្រុមហ៊ុន ហ៊ុយចៀន មានសាខាបួន គឺក្រុមហ៊ុនធំនៅភ្នំពេញ (ហៅថា រោងចក្រប្រាំមួយជាន់) និងសាខានៅខេត្តតាកែវ និងសាខាពីរផ្សេងទៀត ប៉ុន្តែភាគីនិយោជកមិនបានបញ្ជាក់ថា សាខាពីរទៀតនៅទីណាទេ ។

- ក្រុមហ៊ុន ហ៊ុយចៀន (ខេមបូឌា) ខប. មានវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មលេខ ៣៣៣ ពណ.នគក ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៦ ។

- ភាគីរដ្ឋបាល តំណាងឱ្យនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុន ហ៊ុយចៀន មានវិញ្ញាបនប័ត្រចុះបញ្ជិកាពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម តែក្រុមហ៊ុន ហ៊ុយចៀន ទេ ចំណែកឯក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ មានតែវិញ្ញាបនប័ត្រ បើកសាខា ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប៉ុណ្ណោះ មិនមានចុះបញ្ជិកាពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មដាច់ដោយឡែកទេ ។

- ក្រុមហ៊ុន ហ៊ុយចៀន មានថៅកែធំម្នាក់ គឺលោក វ៉ាង វ៉ិនស៊ី (*Mr. WANG, WEN-SHIH*) ចំណែកឯអ្នកគ្រប់គ្រងក្រុមហ៊ុន ហ៊ុយចៀន នៅភ្នំពេញ ឈ្មោះ ឆាលីចាង និងអ្នកគ្រប់គ្រងនៅតាកែវ ឈ្មោះ ហូចៀនស៊ីន ។ អ្នកគ្រប់គ្រងទាំងពីរនាក់នេះ សុទ្ធតែទទួលប្រាក់ខែពីថៅកែធំ (*Mr. WANG, WEN-SHIH*) ដូចគ្នា ។

- តាមរយៈវិញ្ញាបនប័ត្របង្កើតរោងចក្រ លេខ ០៨៦ ឧរថ.កឧ.បរ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ បានចែងថា "*...អនុញ្ញាតឱ្យលោក-លោកស្រី Mr. WANG, WEN-SHIH តំណាងក្រុមហ៊ុន : HUEY CHUEN (CAMBODIA) CORP., LTD. បង្កើតរោងចក្រ*

*ឈ្មោះ ហ៊ុយចៀន (ខេមបូឌា) ខប សាខាទី២ (HUEY CHUEN (CAMBODIA) CORP BRANCH Nº 2) ទីតាំងរោងចក្រ ដីឡូតិ៍លេខ ១៦៨៩ ផ្លូវជាតិលេខ២ ភូមិ ត្រាំ ឃុំរការក្រៅ ស្រុកដូនកែវ ខេត្តតាកែវ...”* ។

ក. ករណីកម្មករនិយោជិត នឹម សារឿន ជឹម វីនយ៉ាវ នឹម សុផាន់ណា និង នៅ សុខឃី

- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតឈ្មោះ នឹម សារឿន ជឹម វីនយ៉ាវ នឹម សុផាន់ណា និង នៅ សុខឃី ត្រូវបានក្រុមហ៊ុនជ្រើសរើសចូលធ្វើការដំបូងនៅទីក្រុងភ្នំពេញ។ កម្មករនិយោជិត នឹម សារឿន ចូលធ្វើការនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៩ ។ កម្មករនិយោជិត ជឹម វីនយ៉ាវ ចូលធ្វើការនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១០ ។ កម្មករនិយោជិត នឹម សុផាន់ណា ចូលធ្វើការនៅថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ។ កម្មករនិយោជិត នៅ សុខឃី ចូលធ្វើការនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១០ ។ តាំងពីជ្រើសរើសចូលធ្វើការដំបូង ពួកគាត់ធ្វើការនៅផ្នែកឃ្លាំងសម្រាប់ទំនិញខេត្តតាកែវ នៅទីតាំងក្រុមហ៊ុន ហ៊ុយចៀន នៅភ្នំពេញ។ កម្មករនិយោជិតក្នុងផ្នែកនេះ មានតួនាទីរៀបចំបើកស្បែកបញ្ជូនទៅសាខាខេត្តតាកែវ និងទទួលស្បែកជើង ដែលដេរពីខេត្តតាកែវ មកឱ្យដាក់បាតនៅក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ ។
- ភាគីកម្មករនិយោជិតបញ្ជាក់បន្ថែមទៀតថា ពេលចូលធ្វើការដំបូង មានមេការពីក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ឈ្មោះ ជូ គ័ន ជាអ្នកជ្រើសរើសឱ្យចូលធ្វើការ ហើយរាល់ការបើកប្រាក់ឈ្នួល និងការឈប់សម្រាកពីការងារ និងការធ្វើការងារផ្សេងៗ គឺស្ថិតក្រោមការគ្រប់គ្រងរបស់មេការ ជូ គ័ន ផ្ទាល់ ដោយមិនពាក់ព័ន្ធនឹងរដ្ឋបាល ក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញទេ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា កម្មករនិយោជិតក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ គ្រប់គ្រងដោយរដ្ឋបាលក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ ហើយកម្មករនិយោជិតក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវគ្រប់គ្រងដោយរដ្ឋបាល ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ។ កម្មករនិយោជិត ហ៊ុយចៀន ភ្នំពេញ មានតារាងប្រាក់ខែ កាត និងរបៀបជ្រើសរើស ផ្សេងពីក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ។
- ភាគីក្រុមហ៊ុនលើកឡើងទៀតថា ក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ និងក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ជាក្រុមហ៊ុនពីរផ្សេងគ្នា ព្រោះមានវិញ្ញាបនប័ត្រ បើកសាខា និងបង់ពន្ធប៉ាតង់ផ្សេងគ្នា។
- សេចក្តីជូនដំណឹងផ្លាស់ប្តូរកន្លែងធ្វើការរបស់រោងចក្រ ហ៊ុយ ចៀន សាខាខេត្តតាកែវ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ បានជូនដំណឹងថា *“ឥឡូវនេះបានទទួលដំណឹងពីរោងចក្រប្រាំមួយជាន់ថា រោងចក្រប្រាំមួយជាន់ បានរៀបចំបង្កើតអ្នកបញ្ជូនឥវ៉ាន់ កែច្នៃ និងស្បែកជើងគំរូបលើទៅរោងចក្រផ្សេងៗទៀត និងមកចេញចូលក្រុមភារកិច្ច ឃ្លាំង នៅរោងចក្រប្រាំមួយជាន់ ។*

*ដូច្នេះហើយរោងចក្រ ហ៊ុយចៀន តាកែវ ពីមុនបានរៀបចំបុគ្គលិកប្រាំមួយនាក់ទៅធ្វើការនៅរោងចក្រប្រាំមួយជាន់ គឺមានឈ្មោះ ជឹង វីនយ៉ាវ អត្តលេខ KH-001 ឈ្មោះ នឹម សារឿន អត្តលេខ KH-*

*003 ឈ្មោះ រ៉េន ស្រីបុល អត្តលេខ KH-006 ឈ្មោះ នឹម សុផាន់ណា អត្តលេខ KH-007 ឈ្មោះនៅ សុខឃី អត្តលេខ KH-008 និងឈ្មោះ សែត កុសល់ អត្តលេខ KH-009*

*តែចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១១តទៅ ប្តូរមកធ្វើការនៅរោងចក្រស្បែកជើង ហ៊ុយចៀន តាកែវវិញ សូមផ្តល់ដំណើងជាពិសេស " ។*

- ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ បញ្ជាក់ជំហរតាមរយៈលិខិតចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១ ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ថា "*...ជារៀងរាល់ឆ្នាំ ចាប់ពីខែមិថុនា រហូតដល់ខែតុលា គឺជារដូវស្ងើយការងារ។ ពីព្រោះរោងចក្រ ហ៊ុយចៀន សាខាខេត្តតាកែវ យើងខ្ញុំ គឺជារោងចក្រកែច្នៃ ដែលទទួលការងារធ្វើពីក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញទៅធ្វើ...ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ សម្រេចធ្វើការផ្លាស់ប្តូរទីតាំងកន្លែងធ្វើការកម្មករនិយោជិតខ្ញុំបាទទាំង ៦ នាក់ ពីក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ ទៅធ្វើការនៅក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ វិញ ដែលមានឈ្មោះ ១. នឹម សារឿន ២. រ៉េន ស្រីបុល ៣. សែត កុសល ៤. ជឹង វិនយ៉ាវ ៥. នៅ សុឃី និង ៦. នឹម សុផាន់ណា សូមជម្រាបក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរថា ចំពោះ ការផ្លាស់ប្តូរទីតាំងធ្វើការរបស់កម្មករខាងលើ ខ្ញុំបាទនឹងគោរពតាមច្បាប់ស្តីពីការងារ ក្នុងការជ្រើសរើសកម្មករឆ្ងាយពីកន្លែងធ្វើការ ដែលមានចែងក្នុងមាត្រាទី ១៨៨ ។ កម្មករនិយោជិតមានសិទ្ធិទទួលបានសោហ៊ុយធ្វើដំណើរត្រឡប់ទៅទីតាំងដែលផ្លាស់ប្តូរ រឺ ថ្លៃឈ្នួលផ្ទះ។ ក្រុមហ៊ុនសម្រេចផ្តល់ជូនក្នុង១នាក់ ១៥ ដុល្លារ/ខែ*" ។
- ភាគីកម្មករនិយោជិតបញ្ជាក់ជំហរថា កម្មករនិយោជិត នឹម សារឿន ជឹម វិនយ៉ាវ នឹម សុផាន់ណា និង នៅ សុខឃី មិនព្រមទៅធ្វើការនៅខេត្តតាកែវ ទេ។

ខ. ករណីកម្មករនិយោជិត វ៉ា គន្ធា

- កម្មករនិយោជិត វ៉ា គន្ធា ចូលធ្វើការនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៦ នៅក្រុមហ៊ុន ហ៊ុយចៀន ភ្នំពេញ ក្រោមកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
- ក្រុមហ៊ុនបញ្ឈប់កម្មករនិយោជិត វ៉ា គន្ធា ពីការងារ នៅមុនការចូលរួមដោះស្រាយនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ ។
- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ហ៊ុយចៀន ធ្វើនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១១ មានឈ្មោះកម្មករនិយោជិត វ៉ា គន្ធា ក្នុងចំណុចទាមទារចូលធ្វើការ ជាមួយនឹងកម្មករនិយោជិត ដែលទាមទារក្នុងសំណុំរឿងនេះដែរ។
- នៅក្នុងកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធ្វើនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១១ បានចែងក្នុងចំណុចមិនសះជាថា "*...សូមឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពស៊ីខូវខ្វ និងសកម្មជន ចូលធ្វើការជាធម្មតាវិញ និងគិតប្រាក់រំលឹកចាប់ពីថ្ងៃបញ្ឈប់*

*របួតដល់ចូលធ្វើការ ដែលមានឈ្មោះដូចខាងក្រោម ជឹម វិនយ៉ាវ, នឹម សារឿន, រ៉េន ស្រីបុល, នឹម សុផាន់ណា, នៅ សុខឃី, សែត សុកល...*" ។

- នៅក្នុងកំណត់ហេតុចំណុចមិនសះជាខាងលើនេះ មិនមានឈ្មោះកម្មករនិយោជិត វ៉ា គន្ធា ទេ ហើយក្នុងកំណត់ហេតុនេះ កម្មករនិយោជិត វ៉ា គន្ធា ក៏បានចុះហត្ថលេខា ក្នុងនាមអ្នកតំណាងឱ្យកម្មករនិយោជិតដែរ។ តាមការអះអាងរបស់ភាគីកម្មករនិយោជិត ការមិនបានសរសេរឈ្មោះកម្មករនិយោជិត វ៉ា គន្ធា ចូលក្នុងកំណត់ហេតុមិនសះជានេះ គឺដោយសារខាងអ្នកផ្សះផ្សាភ្លេចសរសេរចូល ហើយកម្មករនិយោជិតខ្លួនឯង ក៏មិនបានពិនិត្យមើលថា មានឈ្មោះរបស់ខ្លួន ឬអត់។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា ករណីបញ្ឈប់កញ្ញា វ៉ា គន្ធា ពីការងារ ជាផលវិបាកផ្ទាល់នៃវិវាទ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវពិចារណាលើករណីការទាមទាររបស់កម្មករនិយោជិត វ៉ា គន្ធា នៅក្នុងសំណុំរឿងនេះដែរ។

## **ហេតុផលនៃសេចក្ដីសម្រេច:**

**ចំណុចវិវាទទី១ និងទី២: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុន អនុញ្ញាតឱ្យថ្នាក់ដឹកនាំសហជីព និងសកម្មជន ចូលធ្វើការនៅកន្លែងដើមវិញ នៅភ្នំពេញ និងសងប្រាក់រំលឹក**

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាថា តើការទាមទារក្នុងចំណុចនេះ ជាវិវាទអំពីសិទ្ធិដែរ ឬទេ?

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា "*វិវាទអំពីសិទ្ធិ គឺជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់ កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ* "។ (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ *០៥/១១-អ៊ីម រ៉េ (សាខាទី១) ហេតុផលចំណុចវិវាទទី១ និង៥, លេខ ១៧/១១-ហ្គូលកាំរីម៉ិច ហេតុផលចំណុចវិវាទទី១ និង២ និងលេខ ១៨/១១-ជី អេច ជី ហេតុផលចំណុចវិវាទទី៤)* ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងខាងលើដែរ ពោលគឺវិវាទអំពីសិទ្ធិ ជាវិវាទទាក់ទងនឹងសិទ្ធិ ដែលមានចែងក្នុងច្បាប់កិច្ចព្រមព្រៀង ឬអនុសញ្ញារួមណាមួយចែងពីការទាមទារនោះ។ ដោយសារការទាមទារក្នុងចំណុចនេះ ជាការទាមទារពាក់ព័ន្ធនឹងការចូលធ្វើការនៅកន្លែងដើមវិញ ដែលមានចែងក្នុងច្បាប់ស្ដីពីការងារ ហេតុនេះចំណុចវិវាទនេះ ជាចំណុចវិវាទអំពីសិទ្ធិ។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលពិចារណាករណីនេះដូចខាងក្រោម:

ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីព និងសកម្មជនសហជីព មានឈ្មោះ នឹម សារឿន ប្រធានសហជីព ឈ្មោះវ៉ា គន្ធា ជាលេខាធិការសហជីព ឈ្មោះ ជឹម វិនយ៉ាវ ជាសកម្មជនសហជីព ឈ្មោះ នឹម សុផាន់ណា ជាសកម្មជនសហជីព និងឈ្មោះ នៅ សុខឃី ជាសកម្មជនសហជីពចូលធ្វើការវិញ។ រដ្ឋបាលតំណាងឱ្យក្រុមហ៊ុន ហ៊ុយចៀន បញ្ជាក់ថា ករណីកម្មករនិយោជិត ក្រៅពីកម្មករនិយោជិត វ៉ា គន្ធា ជារឿងរបស់

ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ហេតុនេះ ក្រុមហ៊ុន ហ៊ុយចៀន ដែលមានទីតាំងនៅភ្នំពេញមិនដោះស្រាយទេ ចំណែកឯកម្មករនិយោជិត វ៉ា គន្ធា ក្រុមហ៊ុន ហ៊ុយចៀន នៅភ្នំពេញ ក៏មិនដោះស្រាយដែរ ព្រោះមិនមានឈ្មោះក្នុងកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ៊ុយចៀន ដែលបញ្ជូនពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ក. ករណីកម្មករនិយោជិត នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី

មុននឹងពិចារណាដល់ករណីផ្ទេរកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើក្រុមហ៊ុន ហ៊ុយចៀន ជានិយោជករបស់កម្មករនិយោជិតឈ្មោះ នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ដែលទាមទារនៅក្នុងសំណុំរឿងនេះ ឬទេ?

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា *"រូបវន្តបុគ្គល ឬនីតិបុគ្គលជាសាធារណៈ ឬឯកជនទាំងអស់នឹងទុកជានិយោជក ដែលបង្កើតសហគ្រាសតាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ..."*។

មាត្រា ៣ នៃច្បាប់ស្តីពីការងារចែងថា *"កម្មករនិយោជិត តាមន័យនៃច្បាប់នេះ គឺជនគ្រប់ភេទ និងគ្រប់សញ្ជាតិ ដែលបានចុះកិច្ចសន្យាធ្វើការយកកំរៃក្រោមការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលម្នាក់ទៀត ជារូបវន្តបុគ្គល ឬនីតិ បុគ្គលជាសាធារណៈ ឬឯកជន ..."* ។

យោងតាមមាត្រា២ និងមាត្រា៣ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការដឹកនាំ និងគ្រប់គ្រង បានន័យថា បុគ្គលនោះមានសិទ្ធិលើកម្មករនិយោជិតទៅលើការរៀបចំពេលវេលាម៉ោងធ្វើការ ការឈប់សំរាក ការបើកប្រាក់ឈ្នួល ទីកន្លែងបំពេញការងារ ការកំណត់អំពីមធ្យោបាយ-ឧបករណ៍សម្រាប់ការបំពេញការងារ និងលទ្ធផលការងារ ដែលកម្មករនិយោជិតបានបំពេញ ដោយមានសិទ្ធិដាក់វិន័យចំពោះកម្មករនិយោជិត ដែលប្រព្រឹត្តខុស។

នៅក្នុងសំណុំរឿង ៥៣/០៧- អ៊ីហ្គាមេន ហេតុផលចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យលើអង្គហេតុខាងក្រោមនេះ ដើម្បីកំណត់ថា កម្មករនិយោជិតស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រុមហ៊ុន អ៊ីហ្គាមេន ដោយពិនិត្យលើ:

- អ្នកណាជាអ្នកជ្រើសរើសកម្មករនិយោជិតឱ្យចូលធ្វើការ
- អ្នកណាជាអ្នកបង់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត
- អ្នកណាជាអ្នកកំណត់ពេលម៉ោងធ្វើការរបស់កម្មករនិយោជិត
- អ្នកណាជាអ្នកយល់ព្រមលើសំណើសុំច្បាប់ឈប់សម្រាករបស់កម្មករនិយោជិត
- អ្នកណាជាអ្នកដោះស្រាយលើបញ្ហាកំហុសធ្ងន់ ដែលកើតមាន
- អ្នកណាជាអ្នកបញ្ចប់កិច្ចសន្យារបស់កម្មករនិយោជិត

ក្រុមប្រឹក្សាអជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺ និយោជក គឺជាបុគ្គលដែលមានសិទ្ធិលើកម្មករនិយោជិត ទៅលើការរៀបចំពេលវេលាម៉ោងធ្វើការ ការឈប់សម្រាក ការបើកប្រាក់ឈ្នួល ទីកន្លែងបំពេញការងារ ការកំណត់អំពីមធ្យោបាយ-ឧបករណ៍សម្រាប់ការបំពេញការងារ និងលទ្ធផលការងារ ដែលកម្មករនិយោជិតបានបំពេញ ដោយមានសិទ្ធិដាក់វិន័យចំពោះកម្មករនិយោជិត ដែលប្រព្រឹត្តខុស ។

យោងតាមអង្គហេតុ កម្មករនិយោជិត នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ត្រូវបានជ្រើសរើស ឱ្យចូលធ្វើការដោយក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ និងការគ្រប់គ្រងផ្សេងៗទៀត ដូចជាការបើកប្រាក់ឈ្នួល និងការឈប់សម្រាកជាដើម ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវដែរ ។ ដូច្នេះ កម្មករនិយោជិតទាំងនេះជាកម្មករនិយោជិត ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ។

ប៉ុន្តែ យោងតាមអង្គហេតុ ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកធំរបស់ក្រុមហ៊ុន ហ៊ុយចៀន ដែលមានឈ្មោះ Mr. WANG, WEN-SHIH ដូចគ្នានឹងក្រុមហ៊ុន ហ៊ុយចៀន ដែលមានទីតាំងនៅភ្នំពេញដែរ ។ លើសពីនេះទៀត ក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ មិនមានបញ្ជិកាចុះបញ្ជីពាណិជ្ជកម្មដាច់ដោយឡែកពីក្រុមហ៊ុន ហ៊ុយចៀន ដែលមានទីតាំងនៅភ្នំពេញទេ ។ ហេតុនេះ ក្រុមហ៊ុន ហ៊ុយចៀន និងក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ជាក្រុមហ៊ុនតែមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក WANG, WEN-SHIH ជានាយកក្រុមហ៊ុន ។ ដូច្នេះ ក្រុមហ៊ុន ហ៊ុយចៀន ដែលមាននាយកធំឈ្មោះ Mr. WANG, WEN-SHIH ជានិយោជករបស់កម្មករនិយោជិត នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ។

យោងតាមអង្គហេតុ ភាគីនិយោជកបានបញ្ជាក់ជំហរថា ក្រុមហ៊ុនសម្រេចធ្វើការផ្លាស់ប្តូរការងាររបស់កម្មករនិយោជិតឈ្មោះ នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ទៅធ្វើការនៅ ខេត្តតាកែវវិញ ព្រោះកម្មករនិយោជិតទាំងនេះត្រូវបានជ្រើសរើសធ្វើការដំបូងឱ្យក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ ប៉ុន្តែធ្វើការការងារនៅឃ្លាំងទំនិញភ្នំពេញ ដូច្នេះ ករណីនេះ ជាការផ្លាស់ប្តូរកន្លែងការងាររបស់កម្មករនិយោជិតទាំងបួននាក់ខាងលើទៅក្រុមហ៊ុន ហ៊ុយចៀន សាខាខេត្តតាកែវ វិញ ។

**ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើការផ្លាស់ប្តូរកន្លែងការងារនេះសមហេតុផល ឬទេ?**

មាត្រា ២ នៃច្បាប់ស្តីពីការងារចែងថា "*...នឹងទុកជានិយោជកដែលបង្កើតសហគ្រាស តាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ ។ សហគ្រាស ... ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក* "។

ក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រា ២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការងារខាងលើនេះមានន័យថា និយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ល្អីកណាសិទ្ធិនេះ ត្រូវបានធ្វើឡើង ដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ ។ (សូមមើលសេចក្តីបង្គាប់នៃសំណុំរឿងលេខ *១០៨/០៦-ទ្រីនុងហ្គាល កូមាក៉ា ហេតុផលចំណុចវិវាទទី១ និងលេខ ០៨/០៩-កូប៉ល អាបាវែល*)។

បន្ថែមពីនេះ ក្នុងសំណុំរឿងលេខ ១៧/០៣ និង ១៨/០៣-ហូ ហ៊ីង ហេតុផលចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា និយោជកមានសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន រួមមានការផ្ទេរកម្មករនិយោជិតពីកន្លែងមួយទៅកន្លែងមួយ ហើយនិងការផ្តល់ឱ្យនូវលក្ខខណ្ឌមួយចំនួនដូចជា ៖ (១)-មិនកាត់ប្រាក់ឈ្នួល (២)-មិនផ្លាស់ប្តូរកម្មករនិយោជិតទៅកន្លែងឆ្ងាយ (៣)-មិនប្តូរវេនការងារពីថ្ងៃទៅយប់ ឬពីយប់មកថ្ងៃ (៤)-មិនផ្លាស់ប្តូរខុសពីជំនាញខ្លាំងពេក។

យោងតាមមាត្រា២ នៃច្បាប់ស្តីពីការងារ និងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានសិទ្ធិក្នុងការចាត់ចែង ផ្លាស់ប្តូរទីតាំងរបស់ក្រុមហ៊ុនពីកន្លែងមួយទៅកន្លែងមួយ ឬផ្លាស់ប្តូរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ឱ្យតែការផ្លាស់ប្តូរ នោះធ្វើឡើងដោយគោរពលក្ខខណ្ឌទាំង៤ ដើម្បីឱ្យស្របច្បាប់ និងមានលក្ខណៈសមរម្យ។

យោងតាមអង្គហេតុ ការផ្លាស់ប្តូរការងារកម្មករនិយោជិត ឈ្មោះ នីម សារឿន, ជឹម វីនយ៉ាវ, នីម សុផាន់ណា និង នៅ សុខឃី ពីភ្នំពេញទៅធ្វើការនៅខេត្តតាកែវនេះ និយោជកអះអាងថា នឹងគោរពតាមច្បាប់ស្តីពីការងារក្នុងការជ្រើសរើសកម្មករឆ្ងាយពីកន្លែងធ្វើការ ដែលមានចែងក្នុងមាត្រា ១៨៨ នៃច្បាប់ស្តីពីការងារ។ កម្មករនិយោជិតមានសិទ្ធិទទួលបានសោហ៊ុយធ្វើដំណើរត្រឡប់ទៅទីតាំងដែលផ្លាស់ប្តូរ ឬថ្លៃឈ្នួលផ្ទះ ក្រុមហ៊ុនសម្រេចផ្តល់ជូនក្នុង១នាក់ ១៥ ដុល្លារអាមេរិកក្នុងមួយខែ។ ក្រៅពីការផ្តល់ឱ្យនេះ និយោជកមិនបានបញ្ជាក់ថា តើ កម្មករនិយោជិតទាំង ៤ នាក់ ដែលទាមទារក្នុងចំណុចនេះ នឹងទទួលបានប្រាក់ឈ្នួលវេនការងារ និងធ្វើការក្នុងមុខជំនាញដដែលដែរ ឬក៏អត់នោះទេ។ ចំណែកឯចំងាយនៃការផ្លាស់ប្តូរនេះទៀតសោត គឺមានចំងាយឆ្ងាយ ពីភ្នំពេញទៅ ទីតាំងរោងចក្រនៅខេត្តតាកែវ ដីឡូតិ៍លេខ J១៦៤៩ ផ្លូវជាតិលេខ២ ភូមិត្រាំ ឃុំរការក្រៅ ស្រុកដូនកែវ ខេត្តតាកែវ។

ក្រុមប្រឹក្សាអជ្ញាកណ្តាលយល់ឃើញថា ការផ្តល់ប្រាក់ឈ្នួលផ្ទះ ក្នុងម្នាក់ ១៥ ដុល្លារអាមេរិកក្នុងមួយខែ មិនមានភស្តុតាងច្បាស់លាស់ថា កម្មករនិយោជិតទាំងនេះអាចរស់នៅដោយសមរម្យ ដូចធ្វើការនៅភ្នំពេញទេ ព្រោះការទៅរស់នៅទីកន្លែងឆ្ងាយ ត្រូវចំណាយមិនត្រឹមតែលើថ្លៃឈ្នួលផ្ទះទេ នៅមានការប្រែប្រួលលើការចំណាយលើថ្លៃម្ហូបអាហារ ការធ្វើដំណើរនៅទីតាំងថ្មី និងការចំណាយទាក់ទងនឹងជីវភាពប្រចាំថ្ងៃផ្សេងៗទៀត ដែលមិនដូចនឹងការចំណាយពេលធ្វើការនៅភ្នំពេញ ដែលជាទីតាំងចាស់របស់កម្មករនិយោជិតធ្វើការតាំងពីចូលធ្វើការដំបូងមក។

លើសពីនេះទៀត សេចក្តីជូនដំណឹងផ្លាស់ប្តូរកន្លែងធ្វើការរបស់រោងចក្រ ហ៊ុយចៀន សាខាខេត្តតាកែវ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ បានជូនដំណឹងថា *"ឥឡូវនេះបានទទួលដំណឹងពីរោងចក្រប្រាំមួយជាន់ថា រោងចក្រប្រាំមួយជាន់ បានរៀបចំបង្កើតអ្នកបញ្ជូនឥវ៉ាន់ កែច្នៃ និងស្បែកជើងគំរូបលើទៅរោងចក្រផ្សេងៗទៀត និងមកចេញចូលក្រុមភារកិច្ច ឃ្លាំង នៅរោងចក្រប្រាំមួយជាន់។*

*ដូច្នេះហើយ រោងចក្រ ហ៊ុយចៀន តាកែវ ពីមុនបានរៀបចំបុគ្គលិកប្រាំមួយនាក់ទៅធ្វើការនៅ នៅភ្នំពេញប្រាំមួយជាន់គឺមាន ឈ្មោះ ជឹង វីនយ៉ាវ អត្តលេខ KH-001 ឈ្មោះ នីម សារឿន អត្តលេខ KH-003 ឈ្មោះ វ៉េន ស្រីបុល អត្តលេខ KH-006 ឈ្មោះ នីម សុផាន់ណា អត្តលេខ KH-007 ឈ្មោះនៅ សុខឃី អត្តលេខ KH-008 នឹង ឈ្មោះ សែត កុសល់ អត្តលេខ KH-009*

*តែចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១១តទៅ ប្តូរមកធ្វើការនៅរោងចក្រស្បែកជើង ហ៊ុយចៀន តាកែវវិញ សូមផ្តល់ដំណឹងជាពិសេស "* ។

យោងតាមលិខិតជូនដំណឹងនេះ មានន័យថា ការផ្លាស់ប្តូរកម្មករនិយោជិត ទៅធ្វើការនៅខេត្តតាកែវ គឺដោយសាររោងចក្រនៅភ្នំពេញ (ដែលហៅថា រោងចក្រ ប្រាំមួយជាន់) បានរៀបចំកម្មករនិយោជិតថ្មីឱ្យធ្វើការនៅផ្នែកដែលកម្មករនិយោជិតនៅតាកែវធ្លាប់ធ្វើ។ ហេតុនេះ ការផ្លាស់ប្តូរនេះ មិនទាក់ទងនឹងការអត់ការងារធ្វើនៅផ្នែក ដែលកម្មករនិយោជិតសាខាខេត្តតាកែវធ្លាប់ធ្វើទេ។

ដូច្នេះ ការចាត់ចែង ផ្លាស់ប្តូរទីតាំងរបស់កម្មករនិយោជិតឈ្មោះ នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ទៅធ្វើការនៅខេត្តតាកែវ គឺមិនមានហេតុផលសមរម្យទេ ព្រោះសិទ្ធិក្នុងការចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុនរបស់និយោជករួមមាន ការផ្ទេរកម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ មិនបានបំពេញលក្ខខណ្ឌនៃសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដែលត្រូវធ្វើឡើង ដោយស្របច្បាប់ និងមានលក្ខណៈសមរម្យដូចរៀបរាប់នៅក្នុងសេចក្តីបង្គាប់មុនៗទេ។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល បង្គាប់ឱ្យនិយោជក ដែលមានលោក WANG, WEN-SHIH ជានាយកធំ ទទួលយកកម្មករនិយោជិតឈ្មោះ នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ចូលធ្វើការកន្លែងដើមវិញ ឬកន្លែងណាមួយ នៅភ្នំពេញតាមការចាត់ចែងរបស់និយោជក ដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ និងសងប្រាក់រំលឹក ចាប់តាំងពីថ្ងៃមិនអនុញ្ញាតឱ្យពួកគាត់ចូលធ្វើការ រហូតដល់ថ្ងៃ ដែលនិយោជកទទួលពួកគេចូលធ្វើការវិញ។

ខ. ករណីកម្មករនិយោជិត វ៉ា គន្ធា

មាត្រា ៣១២ នៃច្បាប់ស្តីពីការងារ ចែងថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬ ជាបញ្ហាកើតក្រោយការធ្វើកំណត់ហេតុជា ផលវិបាកផ្ទាល់នៃការវិវាទនោះតែប៉ុណ្ណោះ ..."* ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែចំណុចវិវាទ ដែលមាននៅក្នុងរបាយការណ៍មិនសះជាប៉ុណ្ណោះ។ ចំណែកឯចំណុចវិវាទ ដែលមិនមាននៅក្នុងរបាយការណ៍មិនសះជា ដែលភាគីលើកឡើងនៅក្នុងសវនាការបញ្ជាក់ពីការទាមទារបន្ថែម ក្រុមប្រឹក្សាអាចធ្វើការពិចារណាបាន លុះត្រាតែចំណុចវិវាទនោះ គឺជាផលវិបាកផ្ទាល់នៃចំណុចវិវាទ ដែលមាននៅក្នុងរបាយការណ៍មិនសះជា។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល*លេខ ១៦/០៦-អិលអេ លេខ ៤២/០៧- សោធន៍ បេ ហេតុផលចំណុចវិវាទទី៣ ០៦/០៨-យីង ឡៃន ហេតុ ផលចំណុចវិវាទទី២ លេខ ៣៤/០៩-សាន់តិច និងលេខ ១៦០/០៩-ខូសម៉ូ តិចស្តាយ*)។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងមុនៗខាងលើដែរ គឺ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាតែចំណុចវិវាទ ដែលមាននៅក្នុងរបាយការណ៍មិន សះជាប៉ុណ្ណោះ។ ចំណែកឯចំណុចវិវាទ ដែលមិនមាននៅក្នុងរបាយការណ៍មិនសះជា ដែលភាគីលើកឡើង

នៅក្នុងសវនាការ បញ្ជាក់ពីការទាមទារបន្ថែម ក្រុមប្រឹក្សាអាចធ្វើការពិចារណាបាន លុះត្រាតែចំណុចវិវាទនោះ គឺជាផលវិបាកផ្ទាល់នៃចំណុចវិវាទ ដែលមាននៅក្នុងរបាយការណ៍មិនសះជា ។

យោងតាមអង្គហេតុ កម្មករនិយោជិត វ៉ា គន្ធា មិនមានឈ្មោះក្នុងរបាយការណ៍មិនសះជារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទេ ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើវិវាទលើករណីបញ្ឈប់កម្មករនិយោជិត វ៉ា គន្ធា ពីការងារនេះ ជាផលវិបាកផ្ទាល់ដូចការអះអាងរបស់កម្មករនិយោជិត ឬទេ ?

យោងតាមអង្គហេតុ និយោជកបញ្ឈប់កម្មករនិយោជិត វ៉ា គន្ធា ពីការងារ តាំងពីមុនពេលដោះស្រាយវិវាទនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈម្ល៉េះ ជាក់ស្តែងនៅពេលសាកសួរព័ត៌មានគឺមានឈ្មោះកម្មករនិយោជិត វ៉ា គន្ធា ទាមទារចូលធ្វើការវិញដែរ ។ ហេតុនេះ ករណីបញ្ឈប់កម្មករនិយោជិតពីការងារ មិនមែនជាផលវិបាកផ្ទាល់ដែលកើតក្រោយវិវាទ ដែលមានក្នុងសំណុំរឿងនេះទេ ពោលគឺវិវាទនេះមានតាំងពីមុនការផ្សះផ្សានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបដិសេធពិចារណា ការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលកម្មករនិយោជិត វ៉ា គន្ធា ចូលធ្វើការវិញ និងសងប្រាក់រំលឹក ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និងហេតុផលដូចបានរៀបរាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចដូចតទៅ:

## សម្រេច និង បង្គាប់

**១- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

**ចំណុចវិវាទទី១ និងទី២ :**

- បង្គាប់ឱ្យនិយោជក ដែលមានលោក Mr. WANG, WEN-SHIH ជានាយកធំ ទទួលយកកម្មករនិយោជិតឈ្មោះ នឹម សារឿន, ជឹម វីនយ៉ាវ, នឹម សុផាន់ណា និង នៅ សុខឃី ចូលធ្វើការកន្លែងដើមវិញ ឬកន្លែងណាមួយទៀតពេញតាមការចាត់ចែងរបស់និយោជក ដោយស្របច្បាប់ និងមានលក្ខណៈសមរម្យ និងសងប្រាក់រំលឹក ចាប់តាំងពីថ្ងៃមិនអនុញ្ញាតឱ្យពួកគាត់ចូលធ្វើការ រហូតដល់ថ្ងៃនិយោជកទទួលពួកគាត់ចូលធ្វើការវិញ ។
- បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យនិយោជកទទួលកម្មករនិយោជិត វ៉ា គន្ធា ចូលធ្វើការវិញ និងសងប្រាក់រំលឹក ។

**ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីសិទ្ធិ:**

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី១នេះ នឹងក្លាយជាស្ថាពរភ្លាម ហើយអនុវត្តចំពោះភាគីតែម្តង ដោយយោងតាមអនុស្សរណៈនៃការយោគយល់គ្នា ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០១០ ។*

**២- សេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍: គ្មាន**

ប្រភេទនៃសេចក្តីបង្គាប់ទាក់ទងនឹងវិវាទអំពីផលប្រយោជន៍:

*សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសេចក្តីសម្រេចផ្នែកទី២នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក:

ឈ្មោះ ៖ **អ៊ុច សុទ្ធី**

ហត្ថលេខា: --------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត:

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា: --------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល:

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា: --------------------------------